# ឆ្នាំមហាករុណាទិគុណ ២០២៥
# មួយនីចរណ្ដោះទៅកាន់សេចក្ដីសង្ឃឹម

*សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ៖ «ពេលវេលាកំណត់សម្រាប់ឆ្នាំមហាករុណាទិគុណបានមក ដល់ជាថ្មីទៀតហើយ ទ្វារដ៏វិសុទ្ធក៏នឹងត្រូវបើកចំហម្ដងទៀត ដាស់ស្មារតីអស់អ្នកជឿ ឲ្យពោរពេញដោយសេចក្ដីសង្ឃឹម ទទួលការសង្គ្រោះ ដោយសារជំនឿ លើអង្គព្រះគ្រីស្ត»*

ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៤
បុណ្យគោរពព្រះគ្រីស្តជាព្រះមហាក្សត្រនៃពិភពលោក

លោកឪពុក ជាទីស្រឡាញ់
បងប្រុស បងស្រី ជាទីស្រឡាញ់
បងប្អូនទាំងអស់ ជាទីស្រឡាញ់

ឆ្នាំដ៏វិសុទ្ធ នៃសាមគ្គីភាព ការលើកលែងទោសឲ្យរួចពីបាប
និងពោរពេញដោយធម៌មេត្តាករុណា

## ១. ឆ្នាំមហាករុណាទិគុណជាអ្វី

ឆ្នាំមហាករុណាទិគុណ ជាព្រឹត្តិការណ៍ដ៏អស្ចារ្យ ដែលបូជនីយសក័ម្នាក់ៗ អាចបានទទួលបទពិសោធអំពីធម៌មេត្តាករុណាឥតព្រំដែនរបស់ព្រះជាម្ចាស់។ ក្នុងប្រពៃណីរបស់ព្រះសហគមន៍កាតូលិក ឆ្នាំមហាករុណាទិគុណ (អាចហៅថាឆ្នាំដ៏វិសុទ្ធ)ណែនាំឲ្យយើងបានផ្សះផ្សារជាមួយព្រះជាម្ចាស់ និងទទួលការប្រោសប្រណីឲ្យរួចពីទោសនៃអំពើបាប។

## ២. បុព្វប្រវត្តិ

ក្នុងសម្ពន្ធមេត្រីចាស់ តាមធម្មវិន័យរបស់លោកម៉ូសេ បានកំណត់ឆ្នាំជាក់លាក់មួយសម្រាប់ជនជាតិយូដា គឺ ជារៀងរាល់៥០ឆ្នាំម្តង កំណត់ជាឆ្នាំមហាករុណាទិគុណ។

ក្នុងសម្ពន្ធមេត្រីថ្មី ព្រះយេស៊ូផ្ទាល់ បានបង្ហាញការបំពេញអត្ថន័យនៃឆ្នាំមហាករុណាទិគុណក្នុងសម្ពន្ធមេត្រីចាស់ ហើយព្រះអង្គ «ប្រកាសអំពីឆ្នាំដែលព្រះជាម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា»(លក៤,១៨)។

ចាប់តាំងពីបើកលើកដំបូងក្នុងឆ្នាំ១៣០០ ឆ្នាំមហាករុណាទិគុណ ក្លាយជាឱកាសពិសេសមួយដើម្បីពង្រឹងជំនឿ លើកទឹកចិត្តឲ្យធ្វើកិច្ចការធម៌មេត្តាការុណា និងការរួបរួមគ្នាជាបងប្អូន ក្នុងព្រះសហគមន៍ និងសង្គម។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ នឹងបើកឆ្នាំមហាករុណាទិគុណ នៅថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០២៤ខាងមុខនេះ នៅទីក្រុងរ៉ូម។

## ៣. ពាក្យស្លោកនិងនិមិត្តសញ្ញា

សម្រាប់ឆ្នាំមហាករុណាទិគុណ២០២៥ សម្តេចប៉ាបបានជ្រើសរើសពាក្យស្លោក «***បូជនីយជនឆ្ពោះទៅកាន់សេចក្តីសង្ឃឹម***»៖ សម្តេចប៉ាប បានអញ្ជើញយើងឲ្យធ្វើដំណើរទាំងអស់គ្នាឆ្ពោះទៅកាន់សេចក្តីសង្ឃឹម ដែលព្រះយេស៊ូគ្រីស្តបានប្រទានដល់មនុស្សលោក ដោយសារព្រះអង្គចាប់កំណើតជាមនុស្ស បានរងទុក្ខលំបាក សោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ។

និមិត្តសញ្ញាមានទម្រង់មនុស្ស៤នាក់ដែលមកពីទិសទាំងបួននៃផែនដី។ ពួកគេនៅជាប់ៗគ្នាបង្ហាញអំពីសាមគ្គីភាព និងភារតភាពជាបងប្អូន ដែលមនុស្សទូទៅ មានចំពោះគ្នាទៅវិញទៅមក។ រូបមនុស្សកំពុងតោងកាន់ឈើឆ្កាង ហើយផ្នែកខាងក្រោមនោះ ឈើឆ្កាងបានក្លាយជាយុថ្កាមួយ។ នេះជាសញ្ញានៃជំនឿ និងសញ្ញានៃសេចក្តីសង្ឃឹមដែលមិនអាចរំលងបានដែរ។

## ៤. ការប្រោសប្រណីឲ្យរួចពីទោសនៃអំពើបាប

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានពន្យល់ថា នៅក្នុងអំឡុងឆ្នាំមហាករុណាទិគុណ ២០២៥ យើងអាចទទួល ការប្រោសប្រណីឲ្យរួចពីទោសនៃអំពើបាប។ ឆ្នាំមហាករុណាទិគុណនេះ «ណែនាំឲ្យយើងរកឃើញ ព្រះហឫទ័យមេត្តាករុណាឥតព្រំដែន របស់ព្រះជាម្ចាស់»។ ការប្រោសប្រណីឲ្យរួចពីទោសនៃអំពើបាប គឺជាការអញ្ជើញឲ្យត្រឡប់ទៅរកព្រះជាម្ចាស់ ដើម្បីទទួលបានលើកលែងទោស ដោយឥតព្រំដែនពីព្រះអម្ចាស់។ ឆ្នាំមហាករុណាទិគុណនេះ ផ្តល់ឲ្យយើងនូវការលើកលែងទោសឲ្យរួចពីបាប ប្រសិនបើដួងចិត្តរបស់យើងព្រមបើកចំហ និងមានចិត្តស្មោះចំពោះព្រះជាម្ចាស់ ជាព្រះបិតាដែលស្រឡាញ់យើងអស់កល្បជានិច្ច។

ការប្រោសប្រណីឲ្យរួចពីទោសនៃអំពើបាប សម្រាប់មនុស្សដែលរស់នៅលើផែនដីនេះ បានកើតតាំងពីពេលដែលព្រះយេស៊ូ បានប្រទានកូនសោរទៅលោកសិលា ព្រះអង្គមានព្រះបន្ទូលថា៖ «ខ្ញុំសូមប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្វីៗដែលអ្នករាល់គ្នាស្រាយនៅលើផែនដីនេះ ព្រះជាម្ចាស់ក៏នឹងស្រាយនៅស្ថានបរមសុខដែរ» (មថ ១៨, ១៨)។ យើងអាចទទួល ការប្រោសប្រណីឲ្យរួចពីទោសនៃអំពើបាបតែម្តងក្នុងមួយថ្ងៃ បន្ទាប់ពីបានបំពេញនូវជំហានមួយចំនួនដ៏ជាក់លាក់។

## ៥. ធ្វើដូចម្តេចដើម្បីទទួលការប្រោសប្រណីឲ្យរួចពីទោសនៃអំពើបាប?

បងប្អូនទាំងឡាយណាដែលរួមដំណើរជាមួយព្រះគ្រីស្ត នៅក្នុងដំណើរបូជនីយនៅតាមទីសក្ការដ្ឋាននៃមហាករុណាទិគុណនៅទីក្រុងរ៉ូម ឬនៅទីសក្ការដ្ឋានដែលបានរៀបចំនៅក្នុងភូមិភាគភ្នំពេញ អាចទទួលការប្រោសប្រណីឲ្យរួចពីទោសនៃអំពើបាប។ ប៉ុន្តែបងប្អូនត្រូវមានឆន្ទៈ ចង់កែប្រែចិត្តគំនិត ហើយខិតខំធ្វើកិច្ចការធម៌មេត្តាករុណាដល់អ្នកជិតខាង។

បងប្អូនដែលមានបំណងទទួល ការប្រោសប្រណីឲ្យរួចពីទោសនៃអំពើបាប ត្រូវអនុវត្តន៍តាមជំហានដូចខាងក្រោម យ៉ាងយឺតពេលវេលា៨ថ្ងៃ ក្រោយមកបានធ្វើបូជនីចរតាមទីសក្ការដ្ឋាននៃឆ្នាំមហាករុណាទិគុណ៖

- ទទួលអគ្គសញ្ញាលើកលែងទោស
- ទទួលព្រះកាយព្រះគ្រីស្តក្នុងអភិបូជា
- ចូលរួមអធិដ្ឋានសម្រាប់សម្តេចប៉ាប រួមជាមួយព្រះនាងម៉ារី និងសន្តបុគ្គលទាំងឡាយ)៖ ដោយសូតធម៌ឱព្រះបិតាមួយចប់ ធម៌បពិត្រព្រះនាងម៉ារីមួយចប់ និងធម៌កោតសរសើរមួយចប់

ម្យ៉ាងវិញទៀត ប្រសិនបើបងប្អូនមិនអាចធ្វើបូជនីចរទៅដល់ទីសក្ការដ្ឋានណាមួយ បងប្អូនអាចបានរួមដំណើរដោយធ្វើកិច្ចការធម៌មេត្តាករុណា ដូចជា សួរសុខទុក្ខអ្នកកំពុងជួបការលំបាក (នៅក្នុងរោងចក្រ ពន្ធនាគារ ចាស់ជរា និងជនមានពិការភាព...) ដែលជាបូជនីកិច្ច បង្ហាញពីវត្តមានរបស់ព្រះគ្រីស្តទៅកាន់បងប្អូន នឹងទទួលការប្រោសប្រណីឲ្យរួចពីទោសនៃអំពើបាប សម្រាប់ឆ្នាំព្រះមហាករុណាទិគុណនេះ។

## ៦. ទីសក្ការដ្ឋាននៃមហាករុណាទិគុណក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ៖

1) មជ្ឈមណ្ឌលសកម្មភាពភូមិភាគភ្នំពេញ (ភ្នំពេញថ្មី) ៖ ទ្វារដ៏វិសុទ្ធ និងទីសក្ការដ្ឋានព្រះហប្ញទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ (ព្រះវិហារ សន្តសិលា និងសន្តប៉ូល)
2) ព្រះសហគមន៍កាតូលិកសន្តយ៉ូសែប(ផ្សារតូច)៖ ទីសក្ការដ្ឋានមរណសាក្សី នៃប្រទេសកម្ពុជា និងព្រះវិហារតូចសន្តយ៉ូសែប
3) ព្រះសហគមន៍កាតូលិក ព្រះនាងម៉ារីក្សត្រីនៃសន្តិភាព (អរិយក្សត្រ)៖ ទីសក្ការដ្ឋានព្រះនាងម៉ារីនៃទន្លេមេគង្គ
4) ព្រះសហគមន៍កាតូលិក សន្តមីកាអែល (ក្រុងព្រះសីហនុ)

## ៧. បើកឆ្នាំមហាករុណាទិគុណ២០២៥

ខ្ញុំនឹងបើកឆ្នាំ មហាករុណាទិគុណជាផ្លូវការ នៅថ្ងៃអាទិត្យទី ៥ ខែមករា ឆ្នាំ២០២៥ នៅពេលយើងជួបជុំ ក្នុងឱកាសបុណ្យព្រះយេស៊ូសម្តែងព្រះអង្គ (Epiphany) នៅមជ្ឈមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ (ភ្នំពេញថ្មី) វេលាម៉ោង៣រសៀល។

## ៨. បូជនីកិច្ចជាមួយព្រះនាងព្រហ្មចារីនីម៉ារី ជាមាតានៃសេចក្ដីសង្ឃឹម

ព្រះនាងម៉ារីបានទទួលនៅក្នុងផ្ទៃពោះរបស់ព្រះនាង ព្រះឱរសយេស៊ូ ដែលជាប្រភពនៃសេចក្ដីសង្ឃឹមរបស់មនុស្សទាំងឡាយ។

- **ព្រះនាងម៉ារី ជាគំរូនៃជំនឿ៖** ព្រះនាងបានជឿលើព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ និងយល់ព្រមទទួលព្រះយេស៊ូក្នុងដួងចិត្តនិងរូបកាយរបស់ព្រះនាង។
- **ព្រះនាងម៉ារីជាស្ពាន៖** ព្រះនាងម៉ារីតែងតែអង្វរព្រះជាម្ចាស់សម្រាប់យើង។ យើងអាចអធិដ្ឋានតាមរយៈព្រះនាង ទូលអង្វរសុំការប្រោសប្រណីដល់យើងម្នាក់ៗ ពីព្រះយេស៊ូជាបុត្រារបស់ព្រះនាង។
- **ព្រះនាងម៉ារីជាសាវ័កដំបូងបង្អស់៖** ព្រះនាងម៉ារីបានដើរតាមព្រះយេស៊ូ ជាបុត្រាតាំងពីថ្ងៃទេវទូតជូនដំណឹង រងទុក្ខលំបាកនៅលើឈើឆ្កាង រហូតដល់ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងឡើងស្ថានបរមសុខ។
- **ព្រះនាងម៉ារីជាគំរូនៃការបម្រើនិងធម៌មេត្តាករុណា៖** ព្រះនាងម៉ារីទៅសួរសុខទុក្ខ និងជួយនាងអេលីសាបែតអស់រយៈពេល៣ខែ។ ព្រះនាងម៉ារីយកចិត្តទុកដាក់ចំពោះភ្ញៀវដែលចូលរួមក្នុងមង្គលការនៅភូមិកាណា។
- **ព្រះនាងម៉ារីបានជឿថាព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងព្រះជាម្ចាស់បានលើកព្រះនាងម៉ារីឡើង ទៅស្ថានបរមសុខមុនគេបង្អស់៖** ព្រះនាងម៉ារីនៅក្បែរឈើឆ្កាង រហូតដល់បញ្ចុះសពរបស់ព្រះយេស៊ូនៅក្នុងផ្នូរ។ ព្រះនាងម៉ារីនៅក្បែរព្រះយេស៊ូដែលកំពុងឡើងស្ថានបរមសុខ រហូតដល់ថ្ងៃព្រះវិញ្ញាណយាងមក។ ព្រះនាងម៉ារី អញ្ជើញយើងឲ្យចូលក្នុងអាថ៌កំបាំងនៃការចាប់កំណើតជាមនុស្ស សោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញរបស់បុត្រាព្រះនាង។

នៅពេលដែលសង្គ្រាមកំពុងកើតមានឡើង បង្កឲ្យមានអស្ថិរភាពក្នុងពិភពលោក សូមយើងទូលអង្វរព្រះនាងម៉ារី ជាមាតានៃសន្តិភាព និងជាមាតានៃក្រុមគ្រួសារទាំងឡាយ ដើម្បីប្រទានសេចក្តសង្ឃឹមជានិច្ច ឲ្យយើងខ្ញុំ។

ក្នុងឆ្នាំ២០២៥នេះ យើងនឹងធ្វើបូជនីចរឆ្ពោះទៅកាន់សេចក្ដីសង្ឃឹម សូមព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះយេស៊ូគ្រីស្ដជួយយើងខ្ញុំ ឲ្យយើងរឹងមាំនៅក្នុងជំនឿនិងឲ្យយើងពោរពេញដោយចិត្តធម៌មេត្តាករុណា ដើម្បីចែករំលែកជូនដល់ពិភពលោកទាំងមូល។

សូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូននៅក្នុងរដូវរង់ចាំ ដែលណែនាំឲ្យយើងត្រៀមចូលនៅក្នុងឆ្នាំមហាករុណាទិគុណ ដែលទៅជាឆ្នាំដ៏វិសុទ្ធសម្រាប់យើងផ្ទាល់ ប្រទេសជាតិ និងពិភពលោកទាំងមូលដែរ។

+លោកអភិបាលអូលីវីយេ ជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា ភូមិភាគភ្នំពេញ

# ពាក្យអធិដ្ឋាន ឆ្នាំព្រះមហាករុណាទិគុណ

ឱព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ!
ព្រះអង្គប្រទានឲ្យយើងខ្ញុំមានជំនឿលើព្រះយេស៊ូគ្រីស្ត
ជាព្រះបុត្រា ជាបងប្រុសរបស់យើងខ្ញុំ  និងជាភ្លើងនៃធម៌មេត្តាករុណា
ដែលបំភ្លឺដួងចិត្តយើងដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ។
សូមឲ្យជំនឿនេះ បំភ្លឺយើងខ្ញុំ ឲ្យបានពោរពេញដោយសេចក្តីសង្ឃឹម
ដើម្បីទទួលព្រះរាជ្យរបស់ព្រះអង្គដែលយាងមក។

សូមព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ កែប្រែយើងខ្ញុំ
ឲ្យក្លាយជាអ្នកបណ្តុះគ្រាប់ពូជនៃដំណឹងល្អដោយមិនចេះនឿយហត់។
សូមឲ្យគ្រាប់ពូជទាំងនោះ កែប្រែដួងចិត្តមនុស្សទាំងអស់
និងសកលលោកទាំងមូល ដើម្បីបង្កើតស្ថានបរមសុខថ្មី
និងផែនដីថ្មី ដែលនាំឲ្យអំណាចរបស់មារសាតាំង
នឹងរលាយបាត់អស់ ហើយសិរីរុងរឿងរបស់ព្រះអង្គ
នឹងភ្លឺចិញ្ចែងចិញ្ចាចអស់កល្បជានិច្ច។

សូមឱ្យព្រះហឫទ័យប្រណីសន្តោសនៃឆ្នាំព្រះមហាករុណាទិគុណ
ដាស់ស្មារតីយើងខ្ញុំឲ្យភ្ញាក់ឡើង ធ្វើបូជនីយេសក៍នៃសេចក្តីសង្ឃឹម
និងផ្ចង់ចិត្តឆ្ពោះទៅស្ថានបរមសុខ។ សូមឱ្យព្រះហឫទ័យប្រណីសន្តោស
នៃឆ្នាំព្រះមហាករុណាទិគុណនេះ នាំមកនូវអំណរសប្បាយ និងសុខសន្តិភាព
ដែលមកពីព្រះអង្គនៅក្នុងពិភពលោកទាំងមូល។

យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ជាព្រះជាម្ចាស់យើងខ្ញុំ
ដែលមានព្រះជន្មគង់នៅអស់កល្បជាអង្វែងតរៀងទៅ។
អាម៉ែន

Franciscus